**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# សេចក្តីសម្រេចចិត្ត
# នៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០២៣
# ថ្ងៃព្រហស្បតិ៍ ១២រោច ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ២៥៦៧
# ត្រូវនឹងថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣

កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០២៣ បានដំណើរការរយៈពេលមួយព្រឹកពេញ នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ នៅសាលប្រជុំ “D” អគារមិត្តភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី ដោយមានការអញ្ជើញចូលរួមពី ថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុមការងារប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ស្ថាប័ន លេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្តទាំង២៥ អង្គការអន្តរជាតិ និងអង្គការសង្គមស៊ីវិល មានចំនួនសរុប ១៦២រូប។

អង្គប្រជុំទាំងមូល បានធ្វើការគោរពថ្លែងនូវអំណរគុណប្រកបដោយកតញ្ញុតាធម៌ដ៏ជ្រាលជ្រៅបំផុតជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានសម្រេចប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់ដាក់ចេញនូវវិធានការដ៏មានប្រសិទ្ធភាពបំផុតរក្សាបាននូវសុខសន្តិភាពសង្គម-សេដ្ឋកិច្ចបានយ៉ាងរឹងមាំ ទោះបីជាស្ថិតក្នុងវិបត្តិសកលធំៗ រួមមានវិបត្តិជំងឺកូវីដ-១៩ វិបត្តិសង្គ្រាមនៅប្រទេសអ៊ុយក្រែន និងជម្លោះពាណិជ្ជកម្មនៃប្រទេសមហាអំណាចសេដ្ឋកិច្ចក៏ដោយ។

ជាបន្ថែម អង្គប្រជុំបានថ្លែងនូវមោទនភាពបំផុតចំពោះភាពជោគជ័យនៃមហាព្រឹត្តិការណ៍កីឡាអាស៊ីអាគ្នេយ៍ លើកទី៣២ និងកីឡាអាស៊ានប៉ារ៉ាហ្គេមលើកទី១២ ឆ្នាំ២០២៣ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះក្រោមការដឹកនាំដ៏ឆ្នើម និងឈ្លាសវៃបំផុត **សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី**។

ជាមួយគ្នានេះ អង្គប្រជុំក៏បានធ្វើការថ្លែងអំណរគុណ និងកោតសរសើរចំពោះគ្រប់ស្ថាប័នទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អន្តរជាតិ អង្គការសង្គមស៊ីវិល បណ្តាញអ្នកផ្ទុកមេរោគអេដស៍ និងបណ្តាញក្រុមប្រជាជនគន្លឹះ ដែលបានប្រឹងប្រែងបន្តចូលរួមការងារឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ទោះបីស្ថិតក្នុងស្ថានភាពដ៏លំបាកចំពោះការប្រឈមធំៗនានាដែលបាន និងកំពុងកើតមានយ៉ាងណាក៏ដោយ។

បន្ទាប់ពីការពិភាក្សាផ្លាស់ប្តូរយោបល់ដ៏ទូលំទូលាយមក សមាជិក សមាជិកាទាំងអស់ បានប្តេជ្ញាបន្តរួមគ្នាក្នុងការប្រយុទ្ធទប់ស្កាត់ និងលុបបំបាត់ការឆ្លងរាលដាលមេរោគអេដស៍ និងក្នុងឆន្ទៈរួមឆ្ពោះទៅបញ្ចប់ជំងឺអេដស៍នៅឆ្នាំ២០២៥ និងចីរភាពកម្មវិធីឆ្លើយតបជំងឺអេដស៍ឆ្នាំ២០២៣-២០២៨ កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០២៣ បានដាក់ចេញនូវការសម្រេចចិត្តដូចតទៅ ៖

១. ជំរុញយុទ្ធសាស្ត្រឆ្ពោះទៅសម្រេចគោលដៅ៩៥ ទី១ (៩៥% ក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍ដែលបានដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ពួកគេ) តាមរយៈការជំរុញការងារបង្ការនៃការចម្លងមេរោគអេដស៍ និងជំងឺអេដស៍ឱ្យកាន់តែមានប្រសិទ្ធភាព និងការជំរុញលើកទឹកចិត្តអ្នកមានការសង្ស័យមកទទួលសេវាធ្វើតេស្តរកមេរោគអេដស៍ឱ្យបានឆាប់រហ័ស។

២. ជំរុញក្រសួងទេសចរណ៍បន្តយន្តការជំរុញលើកទឹកចិត្តដល់ គ្រប់គ្រឹះស្ថានកម្សាន្តសប្បាយ សណ្ឋាគារ និងកន្លែងកម្សាន្តនានានៅទូទាំងប្រទេស ឱ្យចូលរួមអនុវត្តគោលនយោបាយនៃការប្រើប្រាស់ស្រោមអនាម័យ១០០ភាគរយឱ្យបានទូលំទូលាយ។

៣. ជំរុញក្រសួងអប់រំ យុវជន និងកីឡា បង្កើនការងារអប់រំផ្សព្វផ្សាយការយល់ដឹងអំពីមេរោគអេដស៍ និងជំងឺអេដស៍ឱ្យបានទូលំទូលាយនៅតាមសាលារៀន គ្រឹះស្ថានឧត្តមសិក្សា ទាំងរដ្ឋ និងឯកជន ដើម្បីការពារ និងកាត់បន្ថយការឆ្លងមេរោគអេដស៍ក្នុងចំណោមយុវជន។

៤. ជំរុញក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បង្កើនការងារអប់រំផ្សព្វផ្សាយការយល់ដឹងអំពីមេរោគអេដស៍ និងជំងឺអេដស៍ ឱ្យបានទូលំទូលាយដល់កម្មករ កម្មការិនី និងនិយោជិតនៅតាមរោងចក្រ សហគ្រាស នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

៥. ជំរុញមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ (NCHADS) នៃក្រសួងសុខាភិបាល បង្កើន និងពង្រីកតំបន់គ្របដណ្តប់នៃសេវាផ្តល់ឱសថការពារមេរោគអេដស៍ជាមុន (PrEP) នៅតាមបណ្តារាជធានី ខេត្ត។

៦. គាំទ្រការដាក់ចេញនូវគោលនយោបាយជាតិបញ្ចប់ជំងឺអេដស៍នៅឆ្នាំ២០២៥ និងចីរភាពកម្មវិធីឆ្លើយតបជំងឺអេដស៍ឆ្នាំ២០២៣-២០២៨។

ថ្ងៃព្រហស្បតិ៍ ១២រោច ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣

**ប្រធានអង្គប្រជុំ**

**ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

**អៀង_មូលី**